safe work australia

Khmer | ខ្មែរ

# សុខភាព និងសុវត្ថិភាពការងារនៅក្នុងប្រទេសអូស្ត្រាលី៖ ព័ត៌មានសម្រាប់ពលករចំណាកស្រុក និងពហុវប្បធម៌

## មនុស្សគ្រប់រូបនៅក្នុងប្រទេសអូស្ត្រាលីមានសិទ្ធិមានសុខភាពល្អ និងសុវត្ថិភាពនៅកន្លែងធ្វើការ។

ច្បាប់សុខភាព និងសុវត្ថិភាពការងារ ការពារកម្មករទាំងអស់ មិនថាពួកគេត្រូវបានជួលឱ្យធ្វើការក្នុងប្រភេទណានោះទេ (ឧទាហរណ៍ ការជួលកម្លាំងពលកម្ម ការងារម្តងម្កាល) ឬស្ថានភាពទិដ្ឋាការរបស់ពួកគេ។ ច្បាប់នានាដូចគ្នាត្រូវអនុវត្តនៅកន្លែងធ្វើការ និងក្រុមវប្បធម៌ទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី។

### តើអ្នកមានសិទ្ធិអ្វីខ្លះ?

អ្នកមានសិទ្ធិមានសុខភាពល្អ និងសុវត្ថិភាពនៅកន្លែងធ្វើការ រួមទាំងសិទ្ធិដើម្បី៖

1. ធ្វើការនៅកន្លែងមានសុខភាពល្អ និងមានសុវត្ថិភាពជាមួយនឹងគ្រឿងបរិក្ខារ (ឧទាហរណ៍ ងាយស្រួលចូលប្រើប្រាស់បង្គន់អនាម័យ និងទឹកផឹក)
2. ដឹងពីគ្រោះថ្នាក់ដែលអាចកើតមានពីការងាររបស់អ្នក ហើយមានគេបង្ហាញពីរបៀបធ្វើការងារនោះដោយសុវត្ថិភាព
3. ត្រូវបានផ្តល់ឧបករណ៍ និង/ឬសម្លៀកបំពាក់សមរម្យដែលអ្នកត្រូវការដើម្បីធ្វើការដោយសុវត្ថិភាព មុនពេលអ្នកចាប់ផ្តើមធ្វើការ (អ្នកមិនចាំបាច់បង់ប្រាក់សម្រាប់របស់ទាំងនេះទេ)
4. រាយការណ៍ពីបញ្ហាសុខភាព និងសុវត្ថិភាពនានានៅកន្លែងធ្វើការ – និយោជករបស់អ្នកមានកាតព្វកិច្ចផ្លូវច្បាប់ ក្នុងការអនុញ្ញាតឱ្យអ្នកលើកឡើងពីកង្វល់សុខភាព និងសុវត្ថិភាពនានា ហើយវាគឺជាការខុសច្បាប់ក្នុងការដាក់ទណ្ឌកម្មអ្នក ឬបណ្តេញអ្នកពីការងារចំពោះការធ្វើដូច្នេះ
5. បដិសេធមិនធ្វើការ ប្រសិនបើអ្នកមានការព្រួយបារម្ភដោយសមហេតុផលថា វាអាចធ្វើឱ្យអ្នក ឬអ្នកផ្សេងទៀតមានហានិភ័យធ្ងន់ធ្ងរនៃការរងរបួស ឬឈឺ ហើយ
6. មានគេបង្ហាញពីរបៀបរាយការណ៍ការរងរបួស ឬជំងឺនៅកន្លែងធ្វើការ។

### តើនិយោជកត្រូវធ្វើអ្វីខ្លះ ក្រោមច្បាប់សុខភាព និងសុវត្ថិភាពការងារ?

និយោជកត្រូវតែ៖

1. ធ្វើអ្វីៗទាំងអស់ដែលពួកគេអាចធ្វើបានដោយសមហេតុផលដើម្បីការពារសុខភាព និងសុវត្ថិភាពរបស់អ្នក – ទាំងផ្លូវកាយ និងផ្លូវចិត្ត
2. ផ្តល់បរិយាកាសការងារប្រកបដោយសុវត្ថិភាព និងផ្តល់ជំនួយគាំទ្រ
3. ស្វែងរក និងយកហានិភ័យចេញពីកន្លែងធ្វើការរបស់អ្នក – ប្រសិនបើមិនអាចយកចេញបានទេ ពួកគេត្រូវតែធ្វើអ្វីៗទាំងអស់ដែលពួកគេអាចធ្វើបានដោយសមហេតុផល ដើម្បីធ្វើយ៉ាងណាកុំឱ្យនរណាម្នាក់រងរបួស ឬឈឺ
4. ផ្តល់ឱ្យអ្នកនូវការបណ្តុះបណ្តាល ព័ត៌មាន និងការណែនាំ ហើយធ្វើយ៉ាងណាឱ្យអ្នកយល់ដឹងពីការងារដែលអ្នកនឹងធ្វើ និងរបៀបធ្វើការងារនោះដោយសុវត្ថិភាព
5. ផ្តល់ឱ្យអ្នកនូវគ្រឿងបរិក្ខារ ឬសម្លៀកបំពាក់សមរម្យ ដែលអ្នកត្រូវការដើម្បីធ្វើការដោយសុវត្ថិភាព មុនពេលអ្នកចាប់ផ្តើមការងារ
6. និយាយជាមួយអ្នកអំពីសុខភាព និងសុវត្ថិភាពការងារ។ ពួកគេត្រូវតែឆ្លើយសំណួររបស់អ្នក ហើយស្តាប់ទស្សនៈនានារបស់អ្នក
7. បង្ហាញអ្នកពីរបៀបរាយការណ៍ពីការរងរបួស ឬជំងឺនៅកន្លែងធ្វើការ។

## តើហានិភ័យគឺជាអ្វី?

ហានិភ័យគឺជាអ្វីៗដែលអាចបង្កគ្រោះថ្នាក់ដល់អ្នកខាងផ្លូវកាយ ឬផ្លូវចិត្តនៅកន្លែងធ្វើការ រួមមាន៖

- ធ្វើការផុតពីដី (ឧទាហរណ៍ ឡើងជណ្ដើរយកឥវ៉ាន់ទៅដាក់លើធ្នើរ ឬធ្វើការលើដំបូល)
- ធ្វើការជាមួយអគ្គិសនី
- ការលើក ឬរើបន្ទុកធ្ងន់ៗ ឬធំ
- ធ្វើការនៅកន្លែងក្ដៅ ឬត្រជាក់ខ្លាំង
- សំឡេងខ្លាំងៗ
- ធ្វើការជាមួយគ្រឿងចក្រ ឬគ្រឿងបរិក្ខារ (ឧទាហរណ៍ នៅក្នុងរោងចក្រ)
- ធ្វើការជាមួយសារធាតុគីមី (ឧទាហរណ៍ ការងារសំអាត)
- ធ្វើការច្រើនម៉ោង ឬធ្វើការងារធ្ងន់ៗ (ឧទាហរណ៍ ការជីកដោយដៃ ការទាមទារផ្លូវចិត្ត ឬការផ្ដោតអារម្មណ៍ឥតឈប់ឈរ)
- ធ្វើការយូរនៅកន្លែងដដែល (ឧទាហរណ៍ អង្គុយ ឬឈរ ដោយមិនអាចផ្លាស់ទីបានច្រើន ឬសម្រាក)
- ធ្វើការក្នុងទីតាំងឆ្គង ឬជាប់ក្នុងជំហរដដែលក្នុងរយៈពេលយូរ
- ចលនាដដែលៗដ៏យូរ
- ធ្វើការតែម្នាក់ឯង ឬនៅកន្លែងដែលគេពិបាកជួយប្រសិនបើអ្នកត្រូវការ
- ដកដង្ហើមស្រូបធូលី ឬភាគល្អិតៗដែលបង្កគ្រោះថ្នាក់ (ឧទាហរណ៍ នៅកន្លែងសំណង់)
- ការសម្លុតធ្វើបាប និងការបៀតបៀន រួមទាំងការបៀតបៀនពូជសាសន៍ និងផ្លូវភេទ និង
- អាកប្បកិរិយាឈ្លានពាន និងអំពើហិង្សា។

## តើអ្នកអាចរក្សាសុវត្ថិភាពខ្លួនអ្នក និងអ្នកដទៃដោយរបៀបណា?

អ្នកក៏ត្រូវមើលថែសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកនៅកន្លែងធ្វើការ ហើយមិនធ្វើឱ្យអ្នកដទៃមានហានិភ័យផងដែរ។ អ្នកអាចធ្វើដូច្នោះបានដោយ៖

- ទៅធ្វើការបណ្ដុះបណ្ដាលសុខភាព និងសុវត្ថិភាពការងារ ក្នុងម៉ោងការងារដែលត្រូវបានបង់ប្រាក់ឱ្យ និងធ្វើតាមការបណ្ដុះបណ្ដាលដែលអ្នកបានទទួលដើម្បីធ្វើការងាររបស់អ្នក
- សួរសំណួរនានាប្រសិនបើអ្នកមិនយល់ពីការបណ្ដុះបណ្ដាល ឬរបៀបធ្វើការងារដោយសុវត្ថិភាព
- អនុវត្តតាមការណែនាំដោយសមហេតុផលពីនិយោជករបស់អ្នកអំពីរបៀប និងពេលណាដែលត្រូវបំពេញការងារនៅកន្លែងធ្វើការ និងរបៀបប្រើប្រាស់គ្រឿងបរិក្ខារ និងឧបករណ៍ដោយសុវត្ថិភាព ហើយ
- ប្រាប់និយោជករបស់អ្នកអំពីហានិភ័យនានាដែលអ្នកឃើញនៅកន្លែងធ្វើការ។

## តើអ្នកអាចសុំជំនួយពីអ្នកណា?

អ្នកមានសិទ្ធិសួរសំណួរនានាអំពីការងាររបស់អ្នក ហើយនិយាយទៅកាន់អ្នកមើលការខុសត្រូវ អ្នកគ្រប់គ្រង ឬនិយោជករបស់អ្នក ប្រសិនបើអ្នកមានអារម្មណ៍ថាមិនមានសុវត្ថិភាព។ វាមិនអីទេក្នុងការសួរសំណួរនានាអំពីអ្វីដែលអ្នកមិនយល់។

អ្នកក៏អាចនិយាយជាមួយអ្នកតំណាងសុខភាព និងសុវត្ថិភាព (HSR) ផងដែរប្រសិនបើមាន។ HSR គឺជាបុគ្គលិកដែលបានជ្រើសរើសនៅកន្លែងធ្វើការរបស់អ្នក ដែលដឹងអំពីសុខភាព និងសុវត្ថិភាពការងារ ហើយអាចជួយអ្នកពីកង្វល់ណាមួយ។ អ្នកក៏អាចនិយាយជាមួយតំណាងសហជីពរបស់អ្នកផងដែរ ប្រសិនបើអ្នកមានអារម្មណ៍ថាមានអ្វីមួយអយុត្តិធម៌ ឬមិនមានសុវត្ថិភាពនៅកន្លែងធ្វើការ។ សហជីពគឺជាក្រុមមួយដែលការពារ និងថែមសិទ្ធិ និងផលប្រយោជន៍របស់កម្មករនៅក្នុងឧស្សាហកម្ម ឬមុខរបរជាក់លាក់មួយ។

អ្នកអាចធ្វើការឱ្យមនុស្សម្នាក់ ហើយត្រូវបានអ្នកផ្សេងបង់ប្រាក់ឱ្យ (ឧទាហរណ៍ ភ្នាក់ងារជួលកម្លាំងពលកម្ម)។ ពួកគេទាំងពីរទទួលខុសត្រូវក្នុងការធ្វើយ៉ាងណាឱ្យអ្នកមានសុវត្ថិភាពនៅកន្លែងធ្វើការ។ អ្នកអាចនិយាយជាមួយអ្នកណាម្នាក់ ឬអ្នកទាំងពីរអំពីបញ្ហាសុខភាព និងសុវត្ថិភាពការងារណាមួយ។

អ្នកក៏អាចទាក់ទងនិយតករសុខភាព និងសុវត្ថិភាពការងារនៅក្នុងរដ្ឋ ឬដែនដីដែលអ្នកធ្វើការផងដែរ - ពួកគេមានចុះក្នុងបញ្ជីនៅចុងឯកសារនេះ។

### សេវាកម្មបកប្រែ

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ឥតគិតថ្លៃអាចរកបាននៅតាមអនឡាញ នៅ TIS National។ សេវាកម្មនេះបើក 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍ ដែលមានច្រើនជាង 100 ភាសា។

**សុខភាព និងសុវត្ថិភាពការងារនៅក្នុងអូស្ត្រាលី៖ ព័ត៌មានសម្រាប់ពលករចំណាកស្រុក និងពហុវប្បធម៌**

safe work australia

## ចុះបើអ្នករងរបួសនៅកន្លែងធ្វើការ?

ប្រសិនបើអ្នករងរបួស ឬឈឺដោយសារការងាររបស់អ្នក អ្នកគួរតែប្រាប់និយោជកររបស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យពួកគេអាចផ្ដល់ ជំនួយបឋម យកហានិភ័យចេញ ឬធ្វើអ្វីៗទាំងអស់ដែលពួកគេអាចធ្វើបានដោយសមហេតុផល ដើម្បីធ្វើយ៉ាងណាកុំអោយអ្នកឯទៀតរងរបួស ឬឈឺ។

អ្នកក៏គួរទៅជួបវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផងដែរ ដើម្បីទទួលការព្យាបាល និងសុំសំបុត្រពេទ្យ។ អ្នកមានសិទ្ធិជ្រើសរើសវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកដែលអ្នកជួប។

អ្នកអាចធ្វើការទាមទារសំណងសម្រាប់កម្មករ ដើម្បីជួយបង់ថ្លៃព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការចំណាយផ្សេងទៀត (ឧទាហរណ៍ ពេលឈប់ពីការងារ) ពីការរងរបួស ឬជំងឺទាក់ទងនឹងការងាររបស់អ្នក។ នៅប្រទេសអូស្ត្រាលី និយោជកត្រូវតែមានការធានារ៉ាប់រងសំណងរបស់កម្មករ ដើម្បីរ៉ាប់រងលើកម្មករទាំងអស់របស់ពួកគេ រួមទាំងពលករចំណាកស្រុកដែលមានទិដ្ឋាការបណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍ សម្រាប់ការរងរបួស ឬជំងឺដែលបណ្ដាលមកពីការងារ។

ប្រសិនបើអ្នកជាអ្នកម៉ៅការ (ដែលអ្នកអាចជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង ឬមានលេខអាជីវកម្មអូស្ត្រាលី (ABN) អ្នកគួរតែទាក់ទងអាជ្ញាធរសំណងរបស់កម្មករដែលពាក់ព័ន្ធនៅក្នុងរដ្ឋ ឬដែនដីដែលអ្នកធ្វើការ ដើម្បីពិនិត្យមើលថាតើអ្នកត្រូវបានរ៉ាប់រងដោយសំណងរបស់កម្មករដែរឬទេ។ ប្រសិនបើអ្នកមិនមានការធានារ៉ាប់រងទេ អ្នកគួរតែពិចារណារៀបចំការធានារ៉ាប់រងផ្ទាល់ខ្លួនរបស់អ្នក ក្នុងករណីដែលអ្នករងរបួស ឬឈឺដែលបណ្ដាលមកពីការងារ។

> ℹ សម្រាប់ព័ត៌មានទូទៅអំពីនរណាជាអ្នកម៉ៅការ អ្នកអាចទាក់ទង Fair Work Ombudsman តាមទូរសព្ទលេខ 13 13 94 ឬនៅតាមគេហទំព័រ www.fairwork.gov.au/contractors។

ការធានារ៉ាប់រងលើសំណងរបស់កម្មករ ក៏អាចជួយអ្នកឱ្យត្រឡប់ទៅធ្វើការវិញ បន្ទាប់ពីការរងរបួសរបស់អ្នកផងដែរ។ អាជ្ញាធរសំណងរបស់កម្មករនឹងធ្វើការជាមួយអ្នក វេជ្ជបណ្ឌិតរបស់អ្នក និងនិយោជករបស់អ្នក ដើម្បីជួយអ្នកឱ្យត្រឡប់ទៅធ្វើការវិញ។

ដើម្បីស្វែងយល់ពីរបៀបទាមទារសំណង អ្នកអាចទាក់ទងអាជ្ញាធរសំណងរបស់កម្មករនៅក្នុងរដ្ឋ និងដែនដីដែលអ្នកធ្វើការ - ពួកគេមានរាយក្នុងបញ្ជីនៅចុងខិត្តប័ណ្ណព័ត៌មាននេះ។

## សិទ្ធិរបស់អ្នកក្នុងការទទួលបានបៀវត្សរ៍ត្រឹមត្រូវ និងលក្ខខណ្ឌការងារត្រឹមត្រូវ

នៅប្រទេសអូស្ត្រាលី មានបៀវត្សរ៍ និងលក្ខខណ្ឌការងារអប្បបរមា។ Fair Work Ombudsman ជួយនិយោជក និងកម្មករឱ្យយល់ដឹងពីសិទ្ធិ និងការទទួលខុសត្រូវនៅកន្លែងធ្វើការ។ ពួកគេក៏អាចជួយអ្នកឱ្យដឹងពីបៀវត្សរ៍ដែលអ្នកគួរត្រូវបានគេបង់ឱ្យផងដែរ។

Fair Work Ombudsman អាចស៊ើបអង្កេត ប្រសិនបើពួកគេគិតថានរណាម្នាក់បានបំពានច្បាប់កន្លែងធ្វើការ។ ពួកគេអាចនិយាយជាមួយអ្នក ហើយផ្ដល់ដំបូន្មាន ទោះបីជាអ្នកបំពានលក្ខខណ្ឌការងារនៃទិដ្ឋាការរបស់អ្នកក៏ដោយ។

> ℹ អ្នកអាចទាក់ទងអាជ្ញាធរដោះស្រាយពាក្យបណ្ដឹងសមភាពការងារ (Fair Work Ombudsman) តាមទូរសព្ទលេខ 13 13 94 ឬនៅតាមគេហទំព័រ www.fairwork.gov.au។

> ℹ
> ### តើអ្នកទៅកន្លែងណាសម្រាប់ព័ត៌មានបន្ថែម ជំនួយ ឬដំបូន្មានអំពីសុខភាព និងសុវត្ថិភាពរបស់អ្នកនៅកន្លែងធ្វើការ?
>
> ចូលទៅកាន់ Migrant workers (ពលករចំណាកស្រុក) | Safe Work Australia. ព័ត៌មានស្ដីពីសុខភាព និងសុវត្ថិភាពការងារដែលបានបកប្រែ Language hub (មជ្ឈមណ្ឌលភាសា) | Safe Work Australia។
>
> សម្រាប់ជំនួយ ឬដំបូន្មានអំពីសុវត្ថិភាពរបស់អ្នកនៅកន្លែងធ្វើការ អ្នកអាចទាក់ទងនិយតករសុខភាព និងសុវត្ថិភាពការងារ ឬអាជ្ញាធរសំណងរបស់កម្មករនៅក្នុងរដ្ឋ ឬដែនដីរបស់អ្នក – ព័ត៌មានលម្អិតមានផ្ដល់ជូនខាងក្រោម។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ **សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់តាមទូរសព្ទលេខ 131 450**។
>
> អ្នកអាចទាក់ទងសហជីពរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម ជំនួយ ឬដំបូន្មានផងដែរអំពីសុខភាព និងសុវត្ថិភាពរបស់អ្នកនៅកន្លែងធ្វើការ។ ប្រសិនបើអ្នកមិនប្រាកដថាត្រូវហៅទៅសហជីពមួយណាទេ អ្នកអាចទាក់ទង Australian Unions តាមទូរសព្ទលេខ 1300 486 466 ឬនៅតាមគេហទំព័រ www.australianunions.org.au។
>
> អង្គការផ្សេងទៀតដែលអ្នកអាចទាក់ទងបាន អំពីបញ្ហាសុខភាព និងសុវត្ថិភាពការងាររបស់អ្នក មានផ្ដល់ជូនខាងក្រោម។

# សុខភាព និងសុវត្ថិភាពការងារនៅក្នុងអូស្ត្រាលី៖ ព័ត៌មានសម្រាប់ពលករចំណាកស្រុក និងពហុវប្បធម៌

safe work australia

## និយតករសុខភាព និងសុវត្ថិភាពការងារ

ដើម្បីសុំជំនួយ ប្រសិនបើអ្នកកំពុងជួបប្រទះ ឬបានជួបប្រទះបញ្ហាសុខភាព និងសុវត្ថិភាពការងារ ដែលនិយោជករបស់អ្នកមិនបានដោះស្រាយ

**រដ្ឋញូវសៅវែល**
SafeWork NSW
គេហទំព័រ៖ safework.nsw.gov.au
អ៊ីមែល៖ contact@safework.nsw.gov.au
ទូរសព្ទ៖ 13 10 50

**រដ្ឋវិចថូរៀ**
WorkSafe Victoria
គេហទំព័រ៖ worksafe.vic.gov.au
អ៊ីមែល៖ info@worksafe.vic.gov.au
ទូរសព្ទ៖ 1800 136 089 (ការហៅទូរសព្ទដោយឥតគិតថ្លៃ)

**រដ្ឋឃ្វីនស្លែន**
Workplace Health and Safety Queensland, Office of Industrial Relations
គេហទំព័រ៖ worksafe.qld.gov.au
ទូរសព្ទ៖ 1300 362 128

**រដ្ឋអូស្ត្រាលីខាងលិច**
WorkSafe WA
គេហទំព័រ៖ commerce.wa.gov.au/WorkSafe/
អ៊ីមែល៖ safety@dmirs.wa.gov.au
ទូរសព្ទ៖ 1300 307 877

**រដ្ឋអូស្ត្រាលីខាងត្បូង**
SafeWork SA
គេហទំព័រ៖ safework.sa.gov.au
អ៊ីមែល៖ help.safework@sa.gov.au
ទូរសព្ទ៖ 1300 366 255

**ដែនដីរាជធានីអូស្ត្រាលី**
WorkSafe ACT
គេហទំព័រ៖ worksafe.act.gov.au
អ៊ីមែល៖ worksafe@worksafe.act.gov.au
ទូរសព្ទ៖ 13 22 81

**ដែនដីខាងជើង**
NT WorkSafe
គេហទំព័រ៖ worksafe.nt.gov.au
អ៊ីមែល៖ ntworksafe@nt.gov.au
ទូរសព្ទ៖ 1800 019 115

**រដ្ឋថាស្មានៀ**
WorkSafe Tasmania
គេហទំព័រ៖ worksafe.tas.gov.au
អ៊ីមែល៖ wstinfo@justice.tas.gov.au
ទូរសព្ទ៖ 03 6166 4600 (ខាងក្រៅរដ្ឋថាស្មានៀ)
ទូរសព្ទ៖ 1300 366 322 (ខាងក្នុងរដ្ឋថាស្មានៀ)

**កុម្មុំនវែល (Commonwealth)**
ប្រសិនបើអ្នកធ្វើការឱ្យទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី ឬសម្រាប់និយោជកជាតិធំមួយ អ្នកអាចនឹងស្ថិតនៅក្នុងគម្រោង Comcare។
Comcare
គហេទំព័រ៖ comcare.gov.au
អីមលែ៖ whs.help@comcare.gov.au
ទូរសព្ទ៖ 1300 366 979

## អាជ្ញាធរសំណងរបស់កម្មករ

ដើម្បីសុំជំនួយ ប្រសិនបើអ្នកកំពុងស្វែងរកសំណងសម្រាប់ការរងរបួស ឬជំងឺទាក់ទងនឹងការងារ

**រដ្ឋញូវសៅវែល**
State Insurance Regulatory Authority
គេហទំព័រ៖ sira.nsw.gov.au
អ៊ីមែល៖ contact@sira.nsw.gov.au
ទូរសព្ទ៖ 13 10 50

**រដ្ឋវិចថូរៀ**
WorkSafe Victoria
គេហទំព័រ៖ worksafe.vic.gov.au
អ៊ីមែល៖ info@worksafe.vic.gov.au
ទូរសព្ទ៖ 1800 136 089 (ការហៅទូរសព្ទដោយឥតគិតថ្លៃ)

**រដ្ឋឃ្វីនស្លែន**
WorkCover Queensland
គេហទំព័រ៖ worksafe.qld.gov.au
អ៊ីមែល៖ info@workcoverqld.com.au
ទូរសព្ទ៖ 1300 362 128

**រដ្ឋអូស្ត្រាលីខាងលិច**
WorkCover WA
គេហទំព័រ៖ workcover.wa.gov.au
ទូរសព្ទ៖ 1300 794 744

**រដ្ឋអូស្ត្រាលីខាងត្បូង**
ReturnToWorkSA
គេហទំព័រ៖ rtwsa.com
អ៊ីមែល៖ info@rtwsa.com
ទូរសព្ទ៖ 13 18 55

**ដែនដីរាជធានីអូស្ត្រាលី**
WorkSafe ACT
គេហទំព័រ៖ worksafe.act.gov.au
អ៊ីមែល៖ worksafe@worksafe.act.gov.au
ទូរសព្ទ៖ 13 22 81

**ដែនដីខាងជើង**
NT WorkSafe
គេហទំព័រ៖ worksafe.nt.gov.au
អ៊ីមែល៖ datantworksafe@nt.gov.au
ទូរសព្ទ៖ 1800 250 713

**រដ្ឋថាស្មានៀ**
WorkSafe Tasmania
គេហទំព័រ៖ worksafe.tas.gov.au
អ៊ីមែល៖ wstinfo@justice.tas.gov.au
ទូរសព្ទ៖ 03 6166 4600 (ខាងក្រៅរដ្ឋថាស្មានៀ)

**កុម្មុំនវែល (Commonwealth)**
ប្រសិនបើអ្នកធ្វើការឱ្យទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី ឬសម្រាប់និយោជកជាតិធំមួយ អ្នកអាចនឹងស្ថិតនៅក្នុងគម្រោង Comcare។
Comcare
គហេទំព័រ៖ comcare.gov.au
អីមលែ៖ general.enquiries@comcare.gov.au
ទូរសព្ទ៖ 1300 366 979

## អ្នកក៏អាចនិយាយទៅកាន់ស្ថាប័នណាមួយខាងក្រោមអំពីបញ្ហាសុខភាព និងសុវត្ថិភាពការងាររបស់អ្នកផងដែរ។

### ដើម្បីសួរអំពីបៀវត្សរ៍ និងលក្ខខណ្ឌការងារនានា

Fair Work Ombudsman

គេហទំព័រ៖ www.fairwork.gov.au

ទូរសព្ទ៖ 13 13 94

### ដើម្បីសុំជំនួយប្រសិនបើអ្នកត្រូវបានគេធ្វើបាប

Fair Work Commission

គហេទំព័រ៖ www.fwc.gov.au

ទូរសព្ទទ៖ 1300 799 675

### ដើម្បីសុំជំនួយ ប្រសិនបើអ្នកត្រូវបានគេបៀតបៀនផ្លូវភេទ

សូមទូរសព្ទទៅលេខ 000 ប្រសិនបើស្ថិតក្នុងភាពអាសន្ន
បណ្ដាញទូរសព្ទជំនួយប៉ូលីស
ទូរសព្ទ៖ 131 444

### ដើម្បីសុំជំនួយ ប្រសិនបើអ្នកបានជួបប្រទះការរើសអើង ឬការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការរបស់អ្នក ហើយចង់ធ្វើបណ្ដឹងតវ៉ា

Australian Human Rights Commission
គេហទំព័រ៖ www.humanrights.gov.au
ទូរសព្ទ៖ 1300 656 419

### ដើម្បីសុំជំនួយ ប្រសិនបើអ្នកត្រូវការការគាំទ្រសម្រាប់អំពើហិង្សាពីដៃគូស្និទ្ធស្នាល អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាផ្លូវភេទ

សេវាប្រឹក្សាអំពើហិង្សាពីដៃគូស្និទ្ធស្នាល ក្នុងគ្រួសារ ផ្លូវភេទថ្នាក់ជាតិ
គេហទំព័រ៖ www.1800respect.org.au
ទូរសព្ទ៖ 1800 RESPECT (1800 737 732)

**ក៏អាចមានមជ្ឈមណ្ឌលច្បាប់ ឬអង្គការជំនួយជនចំណាកស្រុក និងពហុវប្បធម៌នៅក្នុងតំបន់មូលដ្ឋានរបស់អ្នក ដែលអ្នកអាចទាក់ទងសម្រាប់ការគាំទ្រផងដែរ។**